ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:........០០៨/១០....គ.ម.ក/ប្រ.ក

# ប្រកាស

## ស្តីពី

## ការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

Downloaded from http://www.khmerlaws.com

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់នូវលក្ខខណ្ឌតម្រូវ នីតិវិធីដើម្បីទទួលស្គាល់បុគ្គលធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងកំណត់អំពីកាតព្វកិច្ចរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-ច្បាប់ (Law) សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ (Anukret) សំដៅដល់អនុក្រឹត្យ លេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ប្រព័ន្ធជាត់ទាត់និងទូទាត់ (Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកបាន ដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់ និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។ ប្រព័ន្ធជាត់ទាត់និងទូទាត់ រួមមាន÷

ក-ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ (Securities Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធជាត់ទាត់និងទូទាត់ ដើម្បីធ្វើការផ្លាស់ប្តូរកម្មសិទ្ធិលើមូលបត្រ រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។



Downloaded from http://www.khmerlaws.com

ខ-ប្រព័ន្ធផាត់ទាត់និងទូទាត់សាច់ប្រាក់ (Cash Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធផាត់ទាត់និងទូទាត់ ដើម្បីធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់ រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

-បុគ្គលដាក់ពាក្យស្នើសុំ (Applicant) សំដៅដល់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

-បុគ្គលិកជាន់ខ្ពស់ (Senior Staff) សំដៅដល់បុគ្គលិកដែលមានឋានៈចាប់ពីអគ្គនាយករហូតដល់នាយកឬប្រធានផ្នែក និងសវនករផ្ទៃក្នុង។

## ជំពូកទី ២

## លក្ខខណ្ឌនៃការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

### ប្រការ ៣.- បុគ្គលដែលអាចធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវដាក់ពាក្យស្នើសុំ និងត្រូវបានទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

### ប្រការ ៤.- ការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវជាធនាគារពាណិជ្ជដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវទទួលបានជាមុននូវលិខិត "មិនជំទាស់" ពីធនាគារជាតិនៃកម្ពុជា។

### ប្រការ ៥.- លក្ខខណ្ឌតម្រូវ

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវ ៖

១-មានក្របខណ្ឌ និងនីតិវិធីអភិបាលកិច្ចសាជីវកម្មរឹងមាំ។

២-មានភាពរឹងមាំខាងផ្នែកហិរញ្ញវត្ថុ និងសមត្ថភាពប្រតិបត្តិការខ្ពស់។

៣-មានធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព និងបទពិសោធន៍ខ្ពស់សមស្រប នៅក្នុងវិស័យមូលបត្រ ធនាគារ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម សម្រាប់ប្រតិបត្តិការ



Downloaded from http://www.khmerlaws.com

ទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងត្រូវមានអត្តចរិតល្អដូចមានចែងក្នុងមាត្រាទ ៤២ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

៤-មានប្រព័ន្ធបច្ចេកវិទ្យា និងយន្តការនានា ដែលធានាឱ្យប្រតិបត្តិការទូទាត់ មានល្បឿនរហ័ស សុវត្ថិភាព និងស្ថេរភាពខ្ពស់។

៥-មានបច្ចេកវិទ្យាដែលធានាការភ្ជាប់ទំនាក់ទំនង ប្រកបដោយប្រសិទ្ធភាព ជាមួយប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ប្រព័ន្ធទូទាត់សាច់ប្រាក់ និងក្រុមហ៊ុនមូលបត្រដែលជាអតិថិជនរបស់ខ្លួនជាដើម។

៦-មានប្រព័ន្ធទ្រទ្រង់ (Back-up System) និងផែនការយថាភាព (Contingency Plan) សមស្រប ដើម្បីកាត់បន្ថយនូវហានិភ័យដែលកើតចេញពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ (Operational Risks) ជាយថាហេតុ។

៧-មាននីតិវិធីច្បាស់លាស់ ក្នុងការផ្តល់សេវានានាដល់អតិថិជនដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រ ក្នុងការទូទាត់សាច់ប្រាក់។

៨-គោរពតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធនានារបស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ។

### ប្រការ ៦.-ឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញបែបបទនៃពាក្យស្នើសុំទៅតាមទម្រង់ដែលបានកំណត់ដោយ **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ÷

១-អាជ្ញាប័ណ្ណធនាគារពាណិជ្ជថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

២-ប័ណ្ណប៉ាតង់ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣-លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៤-លិខិតបញ្ជាក់ពីដើមទុន និងលិខិតបញ្ជាក់ពីប្រាក់តម្កល់ ប្រាក់បម្រុងកាតព្វកិច្ចចេញដោយធនាគារជាតិនៃកម្ពុជា។

៥-ព័ត៌មានពាក់ព័ន្ធនឹងក្របខណ្ឌ និងនីតិវិធីអភិបាលកិច្ចសាជីវកម្ម។

៦-បញ្ជីរាយនាមភាគហ៊ុនិក ដោយបញ្ជាក់ពីចំនួនហ៊ុន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់ភាគហ៊ុនិកនីមួយៗ។



Downloaded from http://www.khmerlaws.com

៧-បញ្ជីរាយនាមអភិបាលក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទីនិងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អភិបាលនីមួយៗ ព្រមទាំងលិខិតថ្កោលទោស។

៨-អង្គការលេខស្តីពីរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន និងបញ្ជីរាយនាមបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធរបស់ក្រុមហ៊ុនដោយបញ្ជាក់ពីតួនាទី និងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនថតចម្លងដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់បុគ្គលិកជាន់ខ្ពស់នីមួយៗ ព្រមទាំងលិខិតថ្កោលទោស។

៩-នីតិវិធីប្រតិបត្តិការពាក់ព័ន្ធនឹងប្រតិបត្តិការដែលជាសកម្មភាពធនាគារ និងប្រតិ-បត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

១០-ផែនការអាជីវកម្មសម្រាប់រយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។

១១-របាយការណ៍ហិរញ្ញវត្ថុ ឬ របាយការណ៍ហិរញ្ញវត្ថុរួមដែលធ្វើសវនកម្មរួច សម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

១២-ផែនការគ្រប់គ្រងហានិភ័យ និងផែនការយថាភាព (Contingency Plan) ដែលមានលក្ខណៈបច្ចុប្បន្នភាព ជាពិសេសសម្រាប់ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំ ផ្តល់ឯកសារបន្ថែម ឬបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងៗទៀត តាមការចាំបាច់។

## ប្រការ ៧.- ការបដិសេធលើពាក្យស្នើសុំ

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដោយផ្អែកលើមូលហេតុដូចខាងក្រោម ÷

១-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញនូវលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងប្រកាសនេះ ឬសេចក្តីណែនាំផ្សេងទៀតដែលធ្វើនៅក្រោមប្រកាសនេះ ឬបទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត។

២-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ទៅ **គ.ម.ក.**មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវកម្ម។



Downloaded from http://www.khmerlaws.com

៤-សេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល មិនត្រូវបានអនុវត្តទាំងស្រុង ឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធរបស់បុគ្គលដាក់ពាក្យស្នើសុំ ÷

ក-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹម-ត្រូវ ដោយប្រការណាមួយ។

ខ-បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិ ដែលការពារសាធារណជនឱ្យចៀសផុតពីការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារតែភាពមិនស្មោះត្រង់ ឬអសមត្ថភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលនោះ ក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ឬក្នុងការគ្រប់គ្រងក្រុមហ៊ុន។

គ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌនៃការទទួល-ស្គាល់ ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

៦-បុគ្គលដាក់ពាក្យស្នើសុំ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥(ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច ÷

ក-នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។

ខ-ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៨-បុគ្គលដាក់ពាក្យស្នើសុំមាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និង



Downloaded from http://www.khmerlaws.com

ហិរញ្ញប្បទានភេរវកម្ម ឬការទទួលស្គាល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ **គ.ម.ក.**មិនត្រូវបដិសេធលើពាក្យស្នើសុំធ្វើជាភ្នាក់ងាររូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់ឱកាសឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើការពន្យល់។

## ជំពូកទី ៣
## ការសម្រេចផ្តល់ការទទួលស្គាល់

### ប្រការ ៨.- រយៈពេលនៃការសម្រេចផ្តល់ការទទួលស្គាល់

បន្ទាប់ពី **គ.ម.ក.** ទទួលបានឯកសារ និងព័ត៌មានពេញលេញពីបុគ្គលដាក់ពាក្យស្នើសុំ អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការទទួលស្គាល់ឬការបដិសេធដល់បុគ្គលដាក់ពាក្យស្នើសុំ ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ខែ។ ករណីអគ្គនាយកនៃ **គ.ម.ក.** ស្នើសុំឱ្យបុគ្គលដាក់ពាក្យស្នើសុំកែប្រែ ឬផ្តល់ព័ត៌មានបន្ថែមនោះ លក្ខខណ្ឌពេលវេលាក្នុងការពិនិត្យនិងសម្រេចត្រូវគិតសាឡើងវិញ ចាប់តាំងពីកាលបរិច្ឆេទដែលព័ត៌មានទាំងនោះ ត្រូវបានផ្តល់ជូនដល់ **គ.ម.ក.**។

### ប្រការ ៩.- សុពលភាពនៃការទទួលស្គាល់

សុពលភាពនៃការទទួលស្គាល់ មានរយៈពេលមិនកំណត់។

### ប្រការ ១០.- តម្លៃនៃការទទួលស្គាល់ប្រចាំឆ្នាំ និងតម្លៃផ្សេងទៀត

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ (ពីរលាន) រៀល។ ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាមានការបដិសេធលើការទទួលស្គាល់ក៏ដោយ។

បុគ្គលដែលទទួលបានការទទួលស្គាល់ ធ្វើជាភ្នាក់ងាររូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ដោយគិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់។ សម្រាប់ឆ្នាំបន្តបន្ទាប់ ភ្នាក់ងាររូទាត់សាច់



Downloaded from http://www.khmerlaws.com

ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែ ដែលទទួលបានការទទួលស្គាល់។

## ជំពូកទី ៤

## ភារកិច្ចរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

### ប្រការ ១១.- ការចាប់ផ្តើមធ្វើអាជីវកម្ម

បន្ទាប់ពីទទួលបានការទទួលស្គាល់ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវចាប់ផ្តើមប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន ក្នុងរយៈពេលយ៉ាងយូរ ០៣(បី)ខែ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់ ឬក្នុងរយៈពេលសមស្រប ដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ១២.- ភារកិច្ចទូទៅរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវ ÷

១-ធ្វើការគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនខ្លួន និងធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់ រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ នៅក្នុងទីផ្សារមូលបត្រ ប្រកបដោយភាពត្រឹមត្រូវ និងតាមកាលកំណត់។

២-ធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

៣-បំពេញប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ឱ្យដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ (Banking Operations)។

៤-ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់នូវរាល់ហានិភ័យ ដែលកើតឡើងពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ។

៥-គោរពយ៉ាងខ្ជាប់ខ្ជួនទៅតាមលក្ខខណ្ឌតម្រូវស្តីអំពីធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងបច្ចេកវិទ្យា សម្រាប់ធានាប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ឱ្យដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

៦-គោរពតាមវិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងវិធានពាក់ព័ន្ធផ្សេងទៀត។



Downloaded from http://www.khmerlaws.com

៧-ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់សេវារបស់ខ្លួន ដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការ។

៨-បំពេញកាតព្វកិច្ចផ្តល់របាយការណ៍និងព័ត៌មាននានា និងកាតព្វកិច្ចដទៃទៀត ឱ្យបានត្រឹមត្រូវ ដូចមានចែងនៅក្នុងច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

**ប្រការ ១៣.– ការគ្រប់គ្រងគណនី**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវធានាថាក្រុមហ៊ុនមូលបត្រដែលជាអតិថិជនរបស់ខ្លួន ដាក់មូលនិធិរបស់អតិថិជនរបស់ពួកគេនៅក្នុងគណនីដាច់ដោយឡែកពីគណនីផ្ទាល់ខ្លួន សម្រាប់ការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ១៤.– ការកំណត់កម្រៃសេវាទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

ការកំណត់កម្រៃសេវានានារបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវទទួលបានការអនុញ្ញាតជាមុនពី **គ.ម.ក.** ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបញ្ញត្តិនានាដែលពាក់ព័ន្ធ។

**ប្រការ ១៥.– ការសុំការអនុញ្ញាត**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ក្នុងករណី ÷

១-បន្ថែម ឬបន្ថយប្រភេទសេវា ដែលអាចធ្វើអោយប៉ះពាល់ដល់ប្រព័ន្ធទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

២-កែប្រែកម្រៃសេវាទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៣-កែទម្រង់ប្រព័ន្ធបច្ចេកវិទ្យា និងយន្តការនានា ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាព និងសុវត្ថិភាពប្រតិបត្តិការនៃការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៤-ផ្អាកជាបណ្តោះអាសន្ន ឬបញ្ឈប់ផ្តល់សេវាទូទាត់សាច់ប្រាក់ដល់អតិថិជនណាមួយរបស់ខ្លួន។

៥-ការវិនិយោគលើធុរកិច្ចផ្សេងទៀតដែលអាចឱ្យប៉ះពាល់ប្រព័ន្ធទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។



Downloaded from http://www.khmerlaws.com

**ប្រការ ១៦.- ការជូនដំណឹង**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹង និងរាយការណ៍ជាបន្ទាន់ជូន **គ.ម.ក.** ក្នុងករណីដូចខាងក្រោម ÷

១-មានការរអាក់រអួលខាងផ្នែកបច្ចេកវិទ្យា ដែលធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

២-មានការសង្ស័យលើអតិថិជនណាមួយ ដែលអាចមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងអំពើល្មើសផ្សេងទៀត។

៣-មានអតិថិជនដែលគ្មានលទ្ធភាពធ្វើការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៤-ករណីផ្សេងទៀតដែលពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលអគ្គនាយកនៃ **គ.ម.ក.** យល់ឃើញថាចាំបាច់។

**ប្រការ ១៧.- ការផ្តល់របាយការណ៍ប្រចាំខែ និងប្រចាំត្រីមាស**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវផ្តល់របាយការណ៍ប្រចាំខែ ក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីចុងខែនីមួយៗ និងរបាយការណ៍ប្រចាំត្រីមាស ក្នុងរយៈពេល ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីចុងត្រីមាសនីមួយៗជូនទៅ **គ.ម.ក.** ដោយបញ្ជាក់អំពីព័ត៌មានដូចខាងក្រោម ÷

១-ចំនួនប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

២-ចំនួនប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រមិនបានសម្រេច និងការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រមិនទាន់បានសម្រេច ដោយធ្វើការរៀបរាប់និងពន្យល់ឱ្យបានច្បាស់លាស់ ព្រមទាំងបញ្ជាក់ឈ្មោះក្រុមហ៊ុនមូលបត្រ និងវិនិយោគិនមូលបត្រ។

៣-ស្ថានភាពសាច់ប្រាក់នៅក្នុងគណនីរបស់អតិថិជន ដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

៤-ព័ត៌មានផ្សេងទៀត ពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលស្នើសុំដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៨.- ការផ្តល់របាយការណ៍ប្រចាំឆ្នាំ**

ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីឆ្នាំសារពើពន្ធ ឬបន្ទាប់ពីពេលវេលាណាមួយ ដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.** ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ



Downloaded from http://www.khmerlaws.com

ត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍អំពីសកម្មភាពទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន នៃឆ្នាំសារពើពន្ធកន្លងទៅ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច និងរបាយការណ៍លម្អិតដូចខាងក្រោម ÷

១-ការកែប្រែនីតិវិធីប្រតិបត្តិការ ក្នុងការផ្តល់សេវានានាក្នុងការទូទាត់សាច់ប្រាក់ពាក់-ព័ន្ធនឹងមូលបត្រ។

២-ការផ្លាស់ប្តូរសមាជិកភាពនៃក្រុមប្រឹក្សាភិបាល។

៣-ការផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ។

៤-ការបញ្ឈប់ផ្តល់សេវាទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដល់អតិថិជនណាមួយ ឬការផ្តល់សេវាទូទាត់សាច់ប្រាក់ជាថ្មី ដល់អតិថិជននោះ។

៥-ការមិនអនុវត្តតាមនីតិវិធីប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ របស់អតិថិជន និងចំណាត់ការផ្សេងៗ។

៦-បញ្ហានានាដែលនាំឱ្យការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ មិនបានសម្រេច។

៧-ការចាត់វិធានការនានា ដើម្បីជំនះលើស្ថានការណ៍លំបាក ឬហានិភ័យផ្សេងៗ ដែលប៉ះពាល់ដល់ការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៨-ព័ត៌មានផ្សេងទៀត ពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលស្នើសុំដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៩.– ការផ្តល់ព័ត៌មានក្នុងករណីការទូទាត់សាច់ប្រាក់មិនបានសម្រេច**

ក្នុងករណីអតិថិជនដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រ គ្មានលទ្ធភាពធ្វើការទូទាត់ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹងទៅឱ្យប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ដោយបញ្ជាក់ឱ្យច្បាស់អំពីអត្តសញ្ញាណរបស់អតិថិជននោះ និងចំនួនទឹកប្រាក់ដែលត្រូវទូទាត់ ឱ្យបានឆាប់ បន្ទាប់ពីការទូទាត់មិនបានសម្រេចកើតមានឡើង។

**ប្រការ ២០.– ការបញ្ឈប់ការផ្តល់សេវាទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដល់អតិថិជន**

ក្នុងករណីភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រផ្អាកជាបណ្តោះអាសន្ន ឬបញ្ឈប់ការផ្តល់សេវាទូទាត់សាច់ប្រាក់ដល់អតិថិជនណាមួយ ក្រោយពីទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដូចមានចែងនៅក្នុងប្រការ ១៥ នៃប្រកាសនេះ ភ្នាក់ងារទូទាត់



Downloaded from http://www.khmerlaws.com

សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឱ្យប្រតិបត្តិករប្រព័ន្ធទូទាត់និងទូទាត់មូលបត្រ។

**ប្រការ២១.- ការកែប្រែលក្ខន្តិកៈក្រុមហ៊ុនការតែងតាំង ឬផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ការតែងតាំង ឬការផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ដល់ **គ.ម.ក.** គិតចាប់ពីកាលបរិច្ឆេទនៃការកែប្រែការតែងតាំង ឬការផ្លាស់ប្តូរ។

**ប្រការ ២២.- ការរក្សាការសម្ងាត់**

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈដែលខ្លួនទទួលបានក្នុងការបំពេញភារកិច្ច លើកលែងតែក្នុងករណី ÷

១-ច្បាប់អនុញ្ញាត។

២-មានការបង្គាប់ពីតុលាការ។

៣-ស្នើឡើងដោយអគ្គនាយកនៃ **គ.ម.ក.** ក្នុងគោលបំណងអនុវត្តការងារ។

**ប្រការ ២៣.- ទំនាស់ផលប្រយោជន៍**

អភិបាលរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រទាំងឡាយណា ដែលមានការពាក់ព័ន្ធពីផលប្រយោជន៍តាមគ្រប់រូបភាព ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ក្នុងការធ្វើសេចក្តីសម្រេចណាមួយ ក្នុងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលធ្វើឡើងដោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អភិបាលនោះត្រូវធ្វើការជូនដំណឹងឱ្យបានទូលំទូលាយ ដល់សមាជិកផ្សេងទៀតរបស់ក្រុមប្រឹក្សាភិបាល តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមួយសមស្របមុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

អភិបាលដែលមានផលប្រយោជន៍ពាក់ព័ន្ធដូចដែលមានចែងក្នុងកថាខណ្ឌទី១ ខាងលើ មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងមិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតធ្វើសេចក្តីសម្រេចនោះឡើយ។



Downloaded from http://www.khmerlaws.com

**ប្រការ ២៤.- ការហាមឃាត់ការទទួលអំណោយ**

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ សហព័ទ្ធ បុព្វញាតិឬបច្ឆាញាតិរបស់ខ្លួនគិតត្រឹមថ្នាក់ទី៣ មិនត្រូវទទួលអំណោយឬផល-ប្រយោជន៍តាមគ្រប់រូបភាព ពីបុគ្គលដែលខ្លួនមានទំនាក់ទំនងអាជីវកម្ម ឬហិរញ្ញវត្ថុជាមួយ នៅក្នុងការបំពេញមុខងារ និងតួនាទីរបស់ខ្លួន ក្នុងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ២៥.- ការត្រួតពិនិត្យដោយ គ.ម.ក.**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រអាចត្រូវបានត្រួតពិនិត្យ ដែលធ្វើឡើងដោយ **គ.ម.ក.** លើស្ថានភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន។

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវផ្តល់កិច្ចសហការល្អដល់មន្ត្រីត្រួតពិនិត្យរបស់ **គ.ម.ក.** ក្នុងគោលដៅធានានូវប្រសិទ្ធភាពការងារ។

## ជំពូកទី ៥

## ទោសប្បញ្ញត្តិ

**ប្រការ ២៦.- វិធានការរដ្ឋបាល**

អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិដឹកនាំកែតម្រង់ ដាក់លក្ខខណ្ឌ ឬដាក់កំហិតបន្ថែម ព្យួរ ឬដកហូតការទទួលស្គាល់ ក្នុងករណីដែលភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូល-បត្រ ៖

១-ទទួលបានការទទួលស្គាល់ដោយមធ្យោបាយក្លែងបន្លំណាមួយ។

២-ល្មើសនឹងលក្ខខណ្ឌនៃការទទួលស្គាល់។

៣-ល្មើសនឹងកាតព្វកិច្ចដែលមានចែងក្នុងប្រកាសនេះ។

៤-មិនធ្វើតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** ក្នុងការកែតម្រង់ផ្សេងៗ។

៥-នៅតែបន្តប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ក្នុងអំឡុងពេលព្យួរការទទួលស្គាល់។



Downloaded from http://www.khmerlaws.com

៦-ផ្អាកជាបណ្តោះអាសន្ន ឬបញ្ឈប់ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដល់អតិថិជន ដោយមិនទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

៧-មិនអាចអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុងទៅបុគ្គលពាក់ព័ន្ធ។

៨-កំពុងស្ថិតនៅក្នុងស្ថានភាពបច្ចេកទេស និង/ឬហិរញ្ញវត្ថុទន់ខ្សោយ ឬកំពុងត្រូវរំលាយ ដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការទៅតាមមូលហេតុស្របច្បាប់។

៩-ប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិផ្សេងទៀត។

**ប្រការ ២៧.-ទណ្ឌកម្មការពិន័យអន្តរការណ៍**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀត ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យមូលបត្រ និងបទប្បញ្ញាត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ ពី ៥០.០០០.០០០(ហាសិបលាន)រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល។ ដោយឡែក ចំពោះការយឺតយ៉ាវក្នុងការបង់ថ្លៃការទទួលស្គាល់ ដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវទទួលការផាកពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ០១ (មួយ) ថ្ងៃ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**ប្រការ ២៨.-គោលការណ៍ណែនាំផ្សេងៗ**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ២៩.-បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។



Downloaded from http://www.khmerlaws.com

**ប្រការ ៣០.- ការអនុវត្ត**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី **២៩** ខែ**មិថុនា** ឆ្នាំ២០១០

**កាត ឈន់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣០ "ដើម្បីអនុវត្ត"
- អគ្គនាយកដ្ឋានរាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Downloaded from http://www.khmerlaws.com